បើអ្នកមានសំនួរ
ឬត្រូវការជំនួយ
ចូរទូរស័ព្ទនៅថ្ងៃនេះតែម្តង

503-223-8197

តំបន់ក្រុងផតឡែន្ឌនិងនៅជុំវិញ

1-800-424-3247

TTY

នៅក្រៅតំបន់ក្រុងផតឡែននឹងនៅជុំវិញ

## ក្រុមប្រឹក្សាច្បាប់ផ្ទែកទីលំនៅ ស្មើភាពគ្នានៃរដ្ឋអូរិហ្គិន

**(Fair Housing Council of Oregon)**

ក្រដាសស្នាមនេះមានជាទំរង់
ផ្សេងទៀតសំរាប់ជនពិការ ។

FAIR HOUSING COUNCIL of Oregon
1020 SW Taylor Street, Suite 700
Portland, Oregon 97205-2512
ទូរស័ព្ទ៖ 503-223-8197 ឬ 1-800-424-3247 (TTY)
បណ្ដាញអ៊ីនធើណិត៖ www.fhco.org, សារអេឡិចត្រូនិក៖ information@fhco.org
ទូរស័ព្ទបណ្ដឹងរបស់ HUD៖ 1-800-877-0246

# កុំឲ្យការ ប្រកាន់លក្ខណៈ ផ្ទែកទីលំនៅ ឃាត់ឃាំងអ្នកបាន!

**Don't Let Housing Discrimination Shut You Out!**

បើអ្នករស់នៅក្នុងរដ្ឋអូរិហ្គិន ឬខោនទីក្លាក រដ្ឋវ៉ាស្ហិងតុន ហើយ កំពុងមានបញ្ហាទីលំនៅ ដោយ មូលហេតុដូចតទៅនេះ សិទ្ធិរបស់ អ្នកក្នុងច្បាប់ផ្ទែកទីលំនៅស្មើភាព គ្នា អាចត្រូវបានគេបំពានហើយ!

FAIR HOUSING COUNCIL of Oregon

[Cambodian]

## តើអ្វីជាច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា?

ច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាហាមឃាត់ការប្រកាន់លក្ខណៈខុសច្បាប់ផ្នែកទីលំនៅ ។ ការប្រកាន់លក្ខណៈគឺខុសច្បាប់ នៅពេលដែលអ្នកត្រូវគេរាប់រកខុសប្លែកពីអ្នកឯទៀតពីព្រោះតែអ្នក ឬជនម្នាក់ទៀតជាសមាជិកនៃក្រុមពិសេសណាមួយ ឬជា"ចំពួកដែលគេការពារ" ។

*"ចំពួកដែលគេការពារ" នៅក្នុងច្បាប់សហព័ន្ធ មានរួមទាំង៖*

- សាសន៍
- ពណ៌សម្បុរ
- សាសនា
- ជាតិកំណើតដើម
- ភេទ
- ពិការភាពខាងសតិបញ្ញាឬខាងរាងកាយ
- លក្ខណៈគ្រួសារ*

*ច្បាប់រដ្ឋអូរិហ្គិន បន្ថែម៖*

- ប្រភពប្រាក់ចំណូល
- លក្ខណៈរៀបការ

*ទីក្រុងខ្លះក៏បន្ថែមផងដែរនូវ៖*

- អាយុ
- ចំណង់ចិត្តផ្នែកភេទ

បើអ្នករស់នៅក្នុងរដ្ឋអូរិហ្គិន ឬនៅក្នុងខោនធីក្លាក រដ្ឋវ៉ាស៊ីងតុន ហើយបញ្ហារបស់អ្នកជាប់ទាក់ទងនឹងចំណុចមួយនៃចំណុចនៅខាងអ្នកអាចទូរស័ព្ទទៅយើងដើម្បីរកពត៌មានថែមទៀត ។

*រួមទាំងការមានគភ៌និងការមានកូននៅក្រោមអាយុ 18 ឆ្នាំនៅក្នុងគ្រួសារ ។ កិច្ចការពារតែមួយសំរាប់លក្ខណៈគ្រួសារគឺនៅពេលដែលទីលំនៅដែលមានលក្ខណៈសម្បត្តិជាទីលំនៅសំរាប់ជនចាស់ជរា ។

## តើខ្ញុំដឹងថាមានការប្រកាន់លក្ខណៈផ្នែកទីលំនៅដោយរបៀបណា?

ការប្រកាន់លក្ខណៈអាចជារឿងច្បាស់លាស់ឬស្មុកស្មាញ ។ នៅខាងក្រោមនេះជាឧទាហរណ៍នៃរបៀបដែលគេម្ចាស់ចាត់ចែងការ ឬអ្នកផ្តល់ទីលំនៅប្រភេទឯទៀតអាចប្រកាន់លក្ខណៈ៖

- បដិសេធឱកាសដើម្បីជួលផ្ទះ ទិញ ឬចរចារផ្នែកទីលំនៅសំរាប់អ្នក ។
- មិនអនុញ្ញាតឲ្យអ្នកបំពេញពាក្យសុំ ឬប្រាប់អ្នកនូវចម្លើយច្បាស់លាស់ស្តីពីពាក្យសុំរបស់អ្នកក្នុងកម្លុងពីរបីថ្ងៃ ។
- ប្រាប់អ្នកថាគ្មានទីលំនៅទំនេរទេ ថ្វីបើការពិតវាមាននៅទំនេរ ។
- បញ្ជូនអ្នកទៅកាន់ទីលំនៅក្នុងកន្លែង សង្កាត់ ឬផ្នែកមួយនៃចំណោមអាគារពិសេសណាមួយ ។
- បដិសេធរូបអ្នកនូវកិច្ចបំរើខាងបង់ប្រាក់កាត់ខែ ការធានារ៉ាប់រង ឬការបង់ប្រាក់កាត់ខែផ្នែកទីលំនៅឯទៀត ពីព្រោះតែការរួមផ្សំនូវជាតិសាសន៍របស់សង្កាត់ ។
- ផ្តាច់អ្នកដាច់ដោយឡែកតែឯង បដិសេធកិច្ចបំរើសំរាប់អ្នក ឬរាប់រកអ្នកខុសប្លែកពីគេ (ឧទាហរណ៍ ថ្លៃឈ្នួលផ្ទះសំរាប់អ្នកថ្លៃជាងគេឯទៀត) ។
- រុកគួនរំខានឬគំរាមកំហែងអ្នក ។
- សួរសំនួរដែលមើលងាយអ្នក ។
- ផ្តល់សំបុត្រដំណឹងបណ្តេញអ្នកចេញ ហើយគ្មានមូលហេតុអ្វីទៀតដែលហាក់ដូចជាកើតមាន (ដូចជា បង់ថ្លៃឈ្នួលផ្ទះមិនទាន់ពេលវេលាជាដើម) ។
- ធ្វើការសង្កេតថា គាត់មិនអាចជួយអ្នកបានទេ ។
- ឲ្យយោបល់ថាអ្នកគួរទាក់ទងជាមួយនរណាផ្សេងទៀត ។
- ប្រាប់អ្នកថាអ្នកមិនអាចចេញប្រាក់ផ្ទាល់ខ្លួនដើម្បីកែប្រែរូបរាងនៃទីលំនៅរបស់អ្នកដែលអ្នកត្រូវការពីព្រោះតែពិការភាព ។
- បដិសេធសំណូមពរសមរម្យរបស់អ្នកដើម្បីសំរួលក្រិត្យវិន័យផ្នែកទីលំនៅដែលអ្នកត្រូវការដោយសារតែពិការភាព ។

## ទុកឲ្យយើងជួយអ្នកដើម្បីការពារសិទ្ធិរបស់អ្នក

នៅពេលណាដែលអ្នកទូរស័ព្ទទៅក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិន យើងនឹងសំភាសអ្នកដើម្បីប្រមូលពត៌មានចាំបាច់ ។ ចូរប្រុងប្រៀបដើម្បីផ្តល់៖

- អាសយដ្ឋាននៃទីលំនៅ
- ឈ្មោះជនដែលជាប់ទាក់ទងក្នុងបញ្ហានេះ
- ឈ្មោះសាក្សីណាមួយ
- ថ្ងៃខែនៃហេតុការណ៍

ក្នុងករណីខ្លះ ក្រុមប្រឹក្សាអាចធ្វើការពិសោធន៍ច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាដែលអាចបញ្ជូនការទាមទាររបស់អ្នកទៅវែងឆ្ងាយថែមទៀត ។ នៅពេលជាមួយគ្នានោះ គេនឹងផ្តល់ពត៌មានអំពីសិទ្ធិផ្លូវច្បាប់និងផ្លូវជ្រើសសំរាប់អ្នក ។

យោងទៅតាមលទ្ធផល យើងអាចបញ្ជូនអ្នកទៅកាន់មេធាវីក្រសួងសិទ្ធិពលរដ្ឋនៃក្រសួងការងារនិងឧស្សាហកម្ម (BOLI) ឬក្រសួងផ្នែកផ្តល់ជំនួយទីលំនៅនិងបង្កើនក្រុងរបស់សហរដ្ឋអាមេរិក (HUD) ការិយាល័យនៃទីលំនៅស្មើភាពគ្នានិងឱកាសស្មើភាពគ្នា ។

*ការបោះពុម្ពនៃកូនផ្ចត់ក្រដាសនេះត្រូវបានឧបត្ថម្ភដោយជំនួយបង្កើនសហគមរបស់ HUD (HUD Community Development Block Grant -CDBG) ហើយនិងក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិន ។ កិច្ចបំរើរចនានិងការបង្កើតត្រូវបានផ្តល់ឲ្យដោយកិច្ចបំរើខាងពាណិជ្ជកម្មនៃក្រសួងបង្កើនសេដ្ឋកិច្ចរដ្ឋអូរិហ្គិន ។*